# សេចក្តីប្រកាសព័ត៌មានរបស់ ម.ស.ម.ក

# ការរឹតត្បិតទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិនិងសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីរួមទាំងការចាប់ខ្លួនសកម្មជនយុវជន ក្នុងទិវាប្រារព្ធខួប៣ឆ្នាំនៃឃាតកម្មលើលោកបណ្ឌិត កែម ឡី

ភ្នំពេញថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩

*ប្រភេទនៃការរំលោភបំពាន ៖ រំលោភលើសេរីភាពមូលដ្ឋាន*

*សិទ្ធិពាក់ព័ន្ធ ៖ សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី*

នៅថ្ងៃប្រារព្ធខួប៣ឆ្នាំ នៃករណីឃាតកម្មលើលោកបណ្ឌិត កែម ឡី ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ អាជ្ញាធរបានរឹតត្បិតយ៉ាងខ្លាំងទៅលើសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងសេរីភាពខាងការបញ្ចេញមតិរបស់សាធារណជនដែលមានបំណងចូលទៅគោរពវិញ្ញាណក្ខន្ធរបស់លោកបណ្ឌិត កែម ឡី។

ដើម្បីប្រារព្ធខួបនៃមរណភាពរបស់លោកបណ្ឌិត កែម ឡី នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ សកម្មជនជាយុវជន និស្សិត និងតំណាងសហជីព និងសង្គមស៊ីវិលបានប្រមូលផ្តុំនៅស្ថានីយប្រេងឥន្ធនៈកាលតិចស្តុបបូកគោក្នុងគោលបំណងពិសារកាហ្វេនិងដាក់កម្រងផ្កា ដើម្បីរំឭកដល់វិញ្ញាក្ខន្ធរបស់លោកបណ្ឌិត កែម ឡី។ តែជាអកុសលអ្នកទាំងនោះត្រូវបានកងម្លាំងចម្រុះរួមមាននគរបាលនិងកងសន្តិសុខប្រមាណ១០០នាក់ ឡោមព័ទ្ធនៅទីកន្លែងនោះ។ អាជ្ញាធរបានរារាំងប្រជាពលរដ្ឋក្នុងការចូលទៅដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធរបស់លោកបណ្ឌិត កែម ឡី នៅមុខស្ថានីយប្រេងឥន្ធនៈ និងបានបង្ខំសកម្មជនដែលកំពុងអង្គុយពិសារកាហ្វេក្នុងស្តាម៉ាតនៃស្ថានីយប្រេងឥន្ធនៈនោះ ឱ្យពួកគេប្តូរអាវដែលមានសម្រង់សម្តីរបស់លោកបណ្ឌិត កែម ឡី ផងដែរ។

ក្នុងពេលព្យាយាមចូលទៅគោរពវិញ្ញាណក្ខន្ធ នគរបាលបានចាប់ខ្លួនយុវជន ៣ នាក់ នៅខាងក្រៅស្ថានីយប្រេងឥន្ធនៈខណៈពួកគេកំពុងកាន់កម្រងផ្កា។ បន្ទាប់មកយុវជនទាំង៣នាក់នោះត្រូវបានឃុំខ្លួននៅប៉ុស្តិ៍នគរបាល។ ក្នុងចំណោមនោះគឺមានយុវជនពីរនាក់ជាបងប្អូនភ្លោះមានឈ្មោះ ជុំ ហួត និងជុំ ហួរ ដែលជាសកម្មជនបរិស្ថានដែលត្រូវបានដោះលែងនៅពេលល្ងាចនៅថ្ងៃដដែល។ យុវជនទី៣ ឈ្មោះ សួង នាគព័ន្ធ ជាសកម្មជនយុវជនត្រូវបានចាប់

ឃុំខ្លួន និងក្រោយមកត្រូវបានបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញដើម្បីសាកសួរនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩។ គាត់ត្រូវព្រះរាជអាជ្ញាចោទប្រកាន់ពី "បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ" ក្រោមមាត្រា៤៩៤ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ ហើយគាត់នឹងត្រូវចៅក្រមស៊ើបសួរសាកសួរបន្ថែមនៅស្អែកទី១២ ខែកក្កដា ឆ្នាំ២០១៩។

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ ដដែលនេះ នគរបាលបានរារាំងសមាជិកគណបក្សប្រជាធិបតេយ្យមូលដ្ឋានប្រហែល២០រូប ខណៈពួកគាត់ចង់ចាកចេញពីទីស្នាក់ការកណ្តាលរបស់គណបក្សក្នុងរាជធានីភ្នំពេញដើម្បីធ្វើដំណើរទៅចូលរួមពិធីបុណ្យខួបលោកបណ្ឌិត កែម ឡី នៅឯស្រុកកំណើតរបស់លោកនៅក្នុងខេត្តតាកែវ។

នៅមុនមួយថ្ងៃនៃថ្ងៃគម្រប់ខួប ៣ឆ្នាំនេះគឺនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៩ នគរបាលបានចាប់ខ្លួនបុគ្គល៤នាក់ផ្សេងៗគ្នាដោយចោទប្រកាន់ពី"បទញុះញង់បង្កចលាចលសង្គម" ដោយសារលក់អាវយឺតដែលមានរូបភាពនិងសម្រង់សម្តីរបស់លោកបណ្ឌិត កែម ឡី ថា "បើអ្នកមិនធ្វើអ្វីសោះក៏គង់នឹងរងគ្រោះដែរ គ្រាន់តែមិនទាន់ដល់វេនអ្នកប៉ុណ្ណោះ"។ អ្នកទាំងបួននោះរួមមានលោក គង់ រ៉ៃយ៉ា ជាអតីតសកម្មជននិស្សិត ព្រមទាំងសមាជិកគ្រួសាររបស់លោក៣ នាក់ទៀត។ ក្រោយមកសមាជិកគ្រួសារទាំង ៣នាក់របស់លោកត្រូវបានដោះលែងវិញ ចំណែក លោក គង់ រ៉ៃយ៉ា ត្រូវបានបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញដើម្បីសាកសួរ។

នៅព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ ព្រះរាជអាជ្ញាសាលាដំបូងរាជធានីភ្នំពេញបានសាកសួរ ហើយចោទប្រកាន់លើលោក គង់ រ៉ៃយ៉ា "ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ" ក្រោមមាត្រា ៤៩៤ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ។ បន្ទាប់មកគាត់ត្រូវបានបញ្ជូនទៅឃុំខ្លួននៅរសៀលថ្ងៃដដែល។ លោក គង់ រ៉ៃយ៉ា ធ្លាប់ត្រូវបានចាប់ខ្លួននិងចោទប្រកាន់ពី "បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ" ក្នុងឆ្នាំ២០១៥ និងត្រូវបានកាត់ទោសដាក់ពន្ធនាគាររយៈពេល ១៨ខែ ទាក់ទងនឹងការបង្ហោះសារលើទំព័រហ្វេសប៊ុកដែលត្រូវបានចោទប្រកាន់ថានាំឱ្យមាន"បដិវត្តន៍ពណ៌"។ លោកត្រូវបានដោះលែងវិញក្នុងឆ្នាំ២០១៧ បន្ទាប់ពីបានអនុវត្តទោសរួច។

អាជ្ញាធរមូលដ្ឋានក៏បានរារាំងនូវការប្រារព្ធពិធីរំឭកខួបនេះនៅខេត្តមួយចំនួនរួមមានកំពង់ចាម និងបន្ទាយមានជ័យផងដែរ។

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ លោកបណ្ឌិត កែម ឡី អ្នកវិភាគនយោបាយនិងអ្នកការពារសិទ្ធិមនុស្សដែលទទួលបានការគោរពយ៉ាងច្រើនពីសាធារណជន ត្រូវបានឃាតករបាញ់សម្លាប់ ខណៈលោកកំពុងពិសាកាហ្វេក្នុងស្តាម៉ាតនៅក្នុងស្ថានីយប្រេងឥន្ធនៈកាលតិចស្តុបបូកគោស្ថិតនៅលើផ្លូវវិថីព្រះមុនីវង្ស ក្នុងរាជធានីភ្នំពេញ៕

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកតស៊ូមតិ នៃ ម.ស.ម.ក តាមរយៈទូរស័ព្ទ៖ +៨៥៥ (០) ៨៨ ៨១ ៤២ ៧៨៣ ឬអ៊ីម៉ែល ៖ yuthyia@cchrcambodia.org។**

--- ចប់---